# ព្រះមហាក្សត្រីសម័យបុរាណដែលបានផ្លាស់ប្តូរមុខមាត់អាណាចក្រខ្មែរៈ ព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវី



***នៅអាស៊ីអាគ្នេយ៍ ក្នុងសតវត្សរ៍ទី១២ អារ្យធម៌ខ្មែរបាននាំមកនូវការអប់រំ ចំណេះដឹងផ្នែកសុខភាព ជំនឿសាសនា និងការបំភ្លឺផ្លូវជូនដល់ប្រជាជនខ្មែរ។ ស្ត្រីពីរនាក់ដែលជាព្រះអគ្គមហេសីរបស់ព្រះបាទ ជ័យវរ្ម័នទី៧ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងភាពជោគជ័យ និងការពង្រីកទឹកដីរបស់ព្រះរាជាណាចក្រខ្មែរ។***

ដោយ ឃីន ផល្លីកា អត្ថបទនេះអាចរកបាននៅគេហទំព័រ **Devata.org**

**ប្រាសាទអង្គរ ប្រទេសកម្ពុជា-** ប្រាសាទអង្គរវត្តគឺជាវត្ថុសម្គាល់ដ៏ល្បីល្បាញបំផុតរបស់ប្រទេសកម្ពុជា ប៉ុន្តែក្រៅពីនេះ ព្រះបាទជ័យវរ្ម័នទី៧ដែលជាព្រះមហាក្សត្រដ៏មានស្នាដៃបានកសាងប្រាសាទធ្វើអំពីថ្មរាប់រយ ប្រាសាទដែលក្នុងនោះរួមមាន ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទអង្គរធំ ប្រាសាទព្រះខ័ន និងប្រាសាទបន្ទាយឆ្មា។ ភាពស្ងប់ស្ងែងដោយសារតែស្នាព្រះហស្ថផ្នែកស្ថាបត្យកម្ម និងជ័យជំនះច្បាំងដណ្តើមទឹកដីរបស់ក្សត្រអង្គនេះបានទាក់ទាញចំណាប់អារម្មណ៍យ៉ាងច្រើន។ ការស្រាវជ្រាវថ្មីៗនេះបានអះអាងថា មានអ្នកផ្តល់ប្រឹក្សាពីរនាក់បានជួយព្រះបាទជ័យវរ្ម័នទី៧ ផ្លាស់ប្តូរដំណើរប្រវត្តិសាស្ត្រខ្មែរ។ ព្រះអគ្គមហេសីទាំងពីរព្រះអង្គរបស់ទ្រង់ គឺព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវី បានជួយជ្រោមជ្រែងព្រះអង្គលើផ្នែកស្ថាបត្យកម្មក្នុងការអភិវឌ្ឍន៍អាណាចក្រខ្មែរអោយលេចចេញជារូបរាងឡើង។

© 2011 All rights reserved. 



**ប្រាសាទអង្គរធំ ប្រាសាទបាយ័ន និងប្រាសាទព្រះខ័ន**

ក្សត្រទាំងបីព្រះអង្គនេះបានរួបរួមគ្នាកសាងស្នាព្រះហស្ដដ៏សំខាន់សម្រាប់កេរ្តិ៍មរតកខ្មែរ មានដូចជា :

ទីមួយៈ ព្រះបាទជ័យវរ្ម័នទី៧ និងព្រះរាជអគ្គមហេសីទាំងពីរព្រះអង្គបានកសាងប្រាសាទដ៏អស្ចារ្យជាច្រើននៅទូទាំងអាស៊ីអាគ្នេយ៍មានដូចជា បូជនីយស្ថានបែបព្រះពុទ្ធសាសនា និងអគារសាធារណៈ ដែលសព្វថ្ងៃនេះបានផ្ដល់ឱ្យប្រទេសកម្ពុជានូវកេរ្តិ៍តំណែលវប្បធម៌ ដែលទាក់ទាញភ្ញៀវបរទេសរាប់លាននាក់មកពីជុំវិញពិភពលោក។

ទីពីរៈ នៅសតវត្សរ៍ទី១២ ក្សត្រដ៏ឈ្លាសវៃទាំងបីព្រះអង្គនេះបានអនុវត្តប្រព័ន្ធសង្គមមួយ ដែលយើងនៅតែអនុវត្តរហូតមកដល់សព្វថ្ងៃនេះ។ ខណៈពេលដែលអឺរ៉ុបស្ថិតនៅយុគសម័យងងឹត ក្សត្រទាំងបីអង្គនេះរាជទានឱ្យទាំង បុរស និងស្ត្រីទទួលបានសិទ្ធិស្មើរគ្នា ក្នុងវិស័យអប់រំ កម្មសិទ្ធិផ្ទាល់ខ្លួន អំណាចផ្នែកនយោបាយ និងការថែទាំសុខភាពសាធារណៈ។ បើទោះបីជាសង្គមបច្ចុប្បន្ននេះកើតឡើងតាមរយៈការតស៊ូ ឬបដិវត្តន៍របស់ប្រជាជនក៏ដោយ ក៏ការផ្លាស់ប្តូរទាំងអស់នេះមានប្រភពកើតចេញពីសមាជិកញាតិវង្សសានុវង្សដែរ។

គម្រោងអភិវឌ្ឍន៍សង្គមជាច្រើនរបស់ក្សត្រទាំងបីអង្គនេះ ត្រូវបានចងក្រងទុកជាឯកសារបានយ៉ាងល្អតាមរយៈការវិភាគលើស្លាបព្យកម្មរបស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវបានសាងសង់ឡើងក្នុងអំឡុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ក្នុងនោះរួមមាន ផ្លូវថ្នល់ ស្ពាន ប្រាសាទតូចៗ សាលាឆទាន និងមន្ទីរពេទ្យ។ យ៉ាងណាមិញ នៅក្នុងកំឡុងពេលនោះ គេពុំសូវបានដឹងទូលំទូលាយអំពីកិច្ចប្រឹងប្រែងរបស់ព្រះមហាក្សត្រីទាំងពីរព្រះអង្គក្នុងការផ្ដល់អំណាច និងលើកកម្ពស់ស្ត្រីនោះទេ។

រូបបដិមាដែលទំនងជារូបរបស់ព្រះមហាក្សត្រីទាំងពីរព្រះអង្គឆ្លុះបង្ហាញឱ្យឃើញនូវភស្តុតាងបន្ថែមស្ដីពីអំណាចរបស់ស្ត្រី និងការចូលរួមរបស់ស្ត្រីនៅក្នុងជួររាជរដ្ឋាភិបាល។ ភស្តុតាងបន្ថែមទៀតដែលមាននៅលើចម្លាក់លៀនលើកំពូលបូជនីយស្ថាន និងចំណារលើផ្ទាំងសិលាចារឹកបង្ហាញពីការយល់ដឹងជាច្រើន ដែលកត់ត្រាទុកពីគំនិតផ្តួចផ្តើមរបស់ក្សត្រីទាំងពីរអង្គនេះទាក់ទិននឹងតម្លៃសង្គម និងសិទ្ធិរបស់ស្ត្រីដែលគំនិតទាំងនេះមិនសូវបានគេដឹងឡើយ។

© 2011 All rights reserved. w w w . p h a l i k a n . c o m



**នៅខ្លោងទ្វារទាំងប្រាំនៃប្រាសាទអង្គរធំ ក្បូត្រទាំងបីអង្គសម្តែងការស្វាគមន៍ភ្ញៀវទេសចរណ៍**

# ការថែទាំសុខភាពទូទៅ និងការអប់រំនៅក្នុងប្រទេសកម្ពុជាសម័យបុរាណ

ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ គេឃើញមានការសាងសង់មន្ទីរពេទ្យ ចំនួន១០២ខ្នងនៅទូទាំងព្រះរាជាណាចក្រខ្មែរ។ នៅក្នុងសៀវភៅឈ្មោះ *Angkor Un Peuple-Un Art* បោះពុម្ពនៅឆ្នាំ១៩៧៦ លោកស្រី **Madeleine Giteau** ដែលជាអតីត ប្រធានសារមន្ទីរជាតិប្រចាំនៅកម្ពុជា ធ្វើការកត់ត្រាឯកសារស្តីពីការគោរពព្រះមហាក្សត្រ ចេញពីផ្ទាំងសិលាចារឹកនៅតាមមន្ទីរពេទ្យ ដែលរៀបរាប់ពីគោលនយោបាយទូទៅរបស់វណ្ណៈទាំងបួន។ ឧទាហរណ៍ ផ្ទាំងសិលាចារឹករបស់ វណ្ណៈ សាយ ហ្វុង ឆ្លុះបង្ហាញពីបុគ្គលិកផ្នែករដ្ឋបាលដែលមានចំនួន៩៨នាក់ គ្រូនាទី ប្រាក់បៀវត្សរ៍ និង បញ្ជីឈ្មោះឱសថស្ថាននៅតាមមន្ទីរពេទ្យរបស់គេ។

ខុសពីអារ្យធម៌ព្រហ្មញ្ញសាសនាដែលកម្រិតការអប់រំសម្រាប់តែបុរស និងវីរជននោះ សាលាវត្តរបស់ព្រះបាទជ័យវរ្ម័នទី៧ គឺជាសាលារៀនដែលបើកចំហ និងជាមជ្ឈមណ្ឌលបណ្តុះបណ្តាលដែលស្វាគមន៍ទាំងបុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រីដូចគ្នា។ នៅលើផ្ទាំងរូបចម្លាក់ពីរនៅប្រាសាទបាយ័នមានរូបព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវីដែលត្រូវបានឆ្លាក់ជារូបសាស្ត្រាចារ្យបង្រៀនសិស្សមួយក្រុម ( សូមមើលរូបភាពខាងក្រោម) ។ ស្របពេលដែលភស្តុតាងរបស់ខ្ញុំបញ្ជាក់យ៉ាងច្បាស់ថារូបចម្លាក់ទាំងនេះគឺជារូបព្រះមហាក្សត្រីទាំងពីរអង្គនោះទស្សនៈស្តីពីសាស្ត្រាចារ្យស្រីគឺជាគំនិតមួយដ៏កំរ។ ដើម្បីឆ្លុះបញ្ចាំងពីប្រព័ន្ធសង្គមទាំងអស់នេះសិលាចារឹកបានជម្រុញឱ្យក្សត្រជំនាន់ក្រោយ និងពួកអភិជនដើរតាមគំរូដ៏ល្អរបស់ព្រះមហាក្សត្រីទាំងពីរព្រះអង្គដោយគាំទ្រកិច្ចការរដ្ឋតាមរយៈបុណ្យកុសល និងរង្វាន់ពីឋានលើ។

© 2011 All rights reserved.



**ការអប់រំលេចនៅលើចម្លាក់លៀនរបស់ប្រាសាទបាយ័ន។ ចម្លាក់ខាងលើបង្ហាញនូវរូបភាព ព្រះមហាក្សត្រីទាំងពីរអង្គ បង្រៀនក្មេងប្រុស និងក្មេងស្រីជាច្រើន។ ចម្លាក់ខាងក្រោមបង្ហាញពីវគ្គបណ្តុះបណ្តាលក្បួនទ័ព។ ក្រុមបុរសត្រូវ បានផ្តល់ការពន្យល់នៅក្នុងថ្នាក់រៀន។**

ជំនឿខ្មែរដ៏សំខាន់ទាំងអស់នេះ មិនត្រឹមតែត្រូវបានឆ្លុះបញ្ចាំងនៅតាមផ្ទាំងសិលាចារឹកដូចទស្សនៈពីមុនប៉ុណ្ណោះទេ។ ភ្ញៀវទេសចរណ៍គ្រប់រូបដែលបានមកទស្សនាប្រាសាទបាយ័ន ប្រាសាទអង្គរធំ និងប្រាសាទបន្ទាយឆ្មា ដើម្បីទាញយកគំរូទាំងបីនេះបានឃើញប្រវត្តិដែលរៀបរាប់ទិដ្ឋភាពដ៏អស្ចារ្យទាំងនេះទៅនឹងប្រជាជនដែលមិនចេះអក្សរ និងមានវណ្ណៈមិនស្មើគ្នា។ សិលាចារឹកដែលឆ្លាក់ជាប់ទាំងនេះមានរូបរាងជាក្បាច់រចនាបថអណ្តែត និងមាននៅតាមកំពូលបូជនីយដ្ឋាន។

## ការគោរពជាសាធារណៈចំពោះព្រះមហាក្សត្រ និងព្រះមហាក្សត្រី

នៅលើផ្ទាំងចម្លាក់លៀនខាងក្នុងជាន់ទីពីរនៃប្រាសាទបាយ័ន ជីវិតរស់នៅរបស់ព្រះមហាក្សត្រ និងព្រះមហាក្សត្រីទាំងបីអង្គនេះហាក់បីដូចឆ្លុះបង្ហាញពីព័ត៌មានស្តីពីសកម្មភាពនៅក្នុងគ្រួសារ សង្គម នយោបាយ និងសកម្មភាពទូទៅរបស់ទ្រង់។ ព្រះមហាក្សត្រីទាំងពីរអង្គភាគច្រើនគង់អមសងខាងព្រះមហាក្សត្រដែលទំនងជាកំពុងពិភាក្សាអំពីកិច្ចការប្រទេសជាតិនៅក្នុងព្រះបរមរាជវាំង។ នៅក្នុងចម្លាក់លៀនដែលបានឆ្លុះបញ្ចាំងពីជីវិតស្នេហា និងជីវិតផ្ទាល់ខ្លួនរបស់ព្រះអង្គ ព្រះនាងជ័យរាជទេវីបានបណ្តើរព្រះមហាក្សត្រ ( សូមមើលរូបថតខាងក្រោម) ។ នៅលើចម្លាក់លៀនខាងក្រៅប្រាសាទបាយ័ន ព្រះមហាក្សត្រីទាំងពីរ បានយាងតាមក្បួនដង្ហែរព្រះមហាក្សត្រ។ នៅក្នុងចម្លាក់លៀនមួយផ្សេងទៀតព្រះមហាក្សត្រីមួយអង្គអង្គុយពីមុខព្រះមហាក្សត្រដោយលើកដៃបួងសួងសុំសុវត្ថិភាពដល់កងទ័ពរបស់ទ្រង់ និងសុំជោគជ័យសម្រាប់សមរភូមិមុខ។

© 2011 All rights reserved. 



**ព្រះមហាក្សត្រីដឹកនាំក្បួនដង្ហែរនៅក្នុងសិលាចារឹក**

ការមើលឃើញរូបព្រះមហាក្សត្រីអង្គុយពីមុខអ្នកចម្បាំងខ្មែរដ៏អស្ចារ្យនេះ (រូបខាងលើ) ឆ្លុះបង្ហាញថាព្រះបាទជ័យវរ្ម័នទី៧ចាត់ទុកព្រះមហាក្សត្រីឥន្ទ្រទេវី ជាអ្នកដឹកនាំក្បួនយុទ្ធសាស្ត្រចម្បាំងដ៏ពូកែ។ ការឆ្លុះបញ្ចាំងនៅក្នុងចម្លាក់លៀនជាច្រើនសង្កត់ធ្ងន់ពីតួនាទីយ៉ាងសំខាន់ដែលព្រះមហាក្សត្រីទាំងពីរអង្គបានដើរតួនៅក្នុងជីវិតរបស់ព្រះបាទជ័យវរ្ម័នទី៧។ ការជាប់ពាក់ព័ន្ធនេះគឺថាព្រះមហាក្សត្រខ្មែរដ៏អស្ចារ្យអង្គនេះអាចមិនដឹងពីមហិច្ឆតារបស់ទ្រង់ទេប្រសិនបើគ្មានព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវីនៅក្បែរទ្រង់ជួយរៀបចំ និងគ្រប់គ្រងអាណាចក្រដ៏ធំរបស់ទ្រង់នោះ។ ដោយការរួបរួមគ្នា ព្រះបាទជ័យវរ្ម័នទី៧ និងព្រះអគ្គមហេសីរបស់ទ្រង់បានក្លាយជាក្សត្រដែលបានផ្លាស់ប្តូរទីក្រុងអង្គរធំរបស់ទ្រង់ឱ្យក្លាយជារាជធានីដែលមានប្រជាជនរស់នៅរហូតដល់មួយលាននាក់នៅក្នុងសតវត្សរ៍ទី១២។

# អំណាចដ៏មានឥទ្ធិពលរបស់ក្សត្រទាំងបីអង្គ

ការតាមដានពីកិត្តិស័ព្ទដ៏មានឥទ្ធិពល និងសកម្មភាពដ៏រស់រវើករបស់ក្សត្រទាំងបីអង្គនេះបានក្លាយជាការចោទសួរពីទស្សនៈប្រវត្តិសាស្ត្រដែលចាត់ទុកព្រះបាទជ័យវរ្ម័នទី៧ និងព្រះរាជអគ្គមហេសីទាំងពីររបស់ព្រះអង្គជាអ្នកសមាធិដ៏ស្ងប់ស្ងាត់។ ប្រវត្តិវិទូមួយចំនួនបានចាត់ទុកក្សត្រទាំងបីអង្គនេះជាអ្នកប្រតិបត្តិសាសនាព្រះពុទ្ធដ៏ស៊ប់តាមរយៈការធ្វើសមាធិដើម្បីស្វែងរកសេចក្តីស្ងប់។ យោងតាមការស្រាវជ្រាវរបស់ខ្ញុំការយល់ឃើញខុសពីនេះបានធ្វើឱ្យមានការយល់ច្រឡំគ្នារវាងព្រះពុទ្ធហីនយាន និងព្រះពុទ្ធមហាយានដែលក្សត្រទាំងបីបានប្រតិបត្តិ។ ធម៌របស់ព្រះពុទ្ធមហាយានមិនត្រឹមតែធ្វើឱ្យក្សត្រទាំងបីអង្គនេះបំភ្លឺខ្លួនឯងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើជាគំរូឱ្យប្រជាជនទាំងអស់ប្រតិបត្តិតាមទ្រង់។

© 2011 All rights reserved. www.phalikan.com



**ព្រះទាំងបីអង្គរបស់ព្រះពុទ្ធមហាយានក្នុងនោះរួមមាន ព្រះពោធិសត្វលោកេស្វរៈ ព្រះពុទ្ធ និងព្រះបញ្ញាបរាមិតា**

ព្រះរបស់ព្រះពុទ្ធមហាយានទាំងបីអង្គនេះបានផ្តល់សេចក្តីគោរពដល់ស្ត្រីតាមរយៈព្រះបញ្ញាបរាមិតាដែលជាព្រះរាជបិតារបស់ព្រះពុទ្ធទាំងអស់។ ព្រះទាំងបីរួមមាន ព្រះពុទ្ធ និង ព្រះពោធិសត្វលោកេស្វរៈដែលតំណាងឱ្យសេចក្តីមេត្តាធម៌របស់ព្រះ និងព្រះបញ្ញាបរាមិតាដែលតំណាងឱ្យភាពអស្ចារ្យនៃបញ្ញាដ៏ឧត្តម។ នៅក្នុងរជ្ជកាលរបស់ទ្រង់អំណាចរបស់ព្រះរាជាទាំងបីអង្គនេះត្រូវបានបង្ហាញនៅក្នុងរូបចម្លាក់ស្ពាន ( ខាងលើ) ហើយត្រូវបានឆ្លាក់នៅតាមបូជនីយស្ថានរបស់ទ្រង់ជាច្រើនកន្លែងទៀតផង ( ខាងក្រោម) ។



ដើមឡើយកំពែងនីមួយៗនេះឆ្លាក់រូបព្រះទាំងបីអង្គរបស់ព្រះពុទ្ធមហាយានជាក្បាច់អណ្តែត ប៉ុន្តែជម្លោះសាសនាបានធ្វើឱ្យមានការដាប់បង្ហាញរូបចម្លាក់របស់ព្រះទាំងបីនេះចេញ។

© 2011 All rights reserved. 

ជាពិសេសនៅទីសក្ការបូជានៅក្នុងព្រះវិហារដែលបច្ចុប្បន្ននេះត្រូវបានស្គាល់ថាជាប្រាសាទតាព្រហ្ម ព្រះទាំងបីអង្គរបស់ព្រះពុទ្ធមហាយានត្រូវបានឆ្លាក់នៅលើផ្ទាំងសិលាកំពស់ពីរម៉ែត។ ប៉ុន្តែរូបបដិមារបស់ព្រះពុទ្ធមហា-យានរាប់ពាន់ផ្ទាំងត្រូវបានបំផ្លិចបំផ្លាញដោយអ្នកគោរពព្រហ្មញ្ញសាសនាក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ( សូមមើលរូបភាពខាងលើ) ។ នៅប្រាសាទតាសោមអ្នកកាន់ព្រហ្មញ្ញសាសនាបានបំផ្លាញកំពូលបូជនីយស្ថានដែលមានឆ្លាក់រូបព្រះពោធិ៍សត្វលោកេស្វរៈនៅតាមខ្លោងប្រាសាទធំៗ ដោយបំបាត់រូបខាងមុខទាំងស្រុងចោល។ នៅតាមកំពូលបូជនីយស្ថានដែលព្រះមហាក្សត្រ និងព្រះមហាក្សត្រីគោរពបូជាព្រះបញ្ញាបរាមិតារូបចម្លាក់របស់ព្រះបញ្ញាបរាមិតា និងព្រះរាជាផ្សេងទៀតត្រូវបានដាប់ ហើយបន្ទាប់មកទៀតត្រូវបានបំផ្លាញទាំងស្រុងតែម្តង ( សូមមើលរូបខាងក្រោម) ។



**អ្នកអភិរក្សជាតិបារាំងបានសាងសង់កំពូលបូជនីយស្ថានដែលបែកបាក់នៅខ្លោងទ្វាប្រាសាទតាសោមឡើងវិញ។**

**នៅខាងឆ្វេងដៃ ព្រះមហាក្សត្របានគោរពបូជាព្រះពោធិ៍សត្វលោកេស្វរៈ**

© 2011 All rights reserved.



**រូបចម្លាក់ខាងឆ្វេងគឺជាកំពូលបូជនីយស្ថានដែលត្រូវបានជួសជុលឡើងវិញដែលបង្ហាញពីរូបភាពឈររបស់ព្រះបញ្ញាបរាមិតាដែលព្រះមហាក្សត្រគោរពបូជាត្រូវបានគេដាប់មុខចោល។ រូបខាងស្តាំកំពូលបូជនីយស្ថានមួយនេះបានបាត់រូបព្រះបញ្ញាបរាមិតា**

# ភស្តុតាងដែលអះអាងពីអ្នកគ្រប់គ្រងដ៏ព្រចះព្រចង់

បើទោះបីជាមានការប៉ុនប៉ងបំផ្លិចបំផ្លាញកេរ្តិ៍តំនែលរបស់ក្សត្រទាំងបីព្រះអង្គនេះក៏ដោយ ក៏ព្រះរាជាទាំងបីអង្គនេះបានទុកចំណារដ៏ច្បាស់លាស់មួយដែលស្តីពីជំនឿរបស់ទ្រង់អស់រយះកាលជាច្រើនឆ្នាំ។ ក្នុងកំឡុងអាណាចក្រខ្មែរព្រះបាទជ័យវរ្ម័នទី៧ និងព្រះមហាក្សត្រីទាំងពីររបស់ព្រះអង្គបានផ្តល់សាររបស់ទ្រង់ដោយប្រើប្រាស់លទ្ធិគោរពសាសនាដែលបង្ហាញការគោរពដល់ស្ត្រីតាមរយះការគោរពព្រះបញ្ញាបរាមិតារបស់ព្រះពុទ្ធមហាយានឈរទន្ទឹមនឹងព្រះពោធិ៍សត្វលោកេស្វរៈ។ ឋានៈនេះមិនត្រូវបានគេឃើញ នៅក្នុងរជ្ជកាលមុនៗទេ ប៉ុន្តែនៅក្នុងរជ្ជកាលព្រះបាទជ័យវ័រន្មទី៧ នៅពេលដែលព្រះពុទ្ធសាសនាមានអំណាចលើព្រហ្មញ្ញសាសនាតួនាទីរបស់ស្ត្រីត្រូវបានលើកតម្កើងជាព្រះដែលធ្វើអោយអ្នកកាន់ព្រហ្មញ្ញសាសនាខឹងសម្បាយ៉ាងខ្លាំង។

នៅចុងបញ្ចប់ព្រហ្មញ្ញសាសនាក៏បានគ្រប់គ្រងប្រទេសអស់មួយរយះកាលដោយធ្វើការបែងចែកឱ្យឃើញថាស្ត្រី គឺគ្មានសារសំខាន់អ្វីទាំងអស់ទាំងនៅក្នុងផ្នែកសាសនា និងសង្គម។ អ្នកកាន់ព្រហ្មញ្ញសាសនាដែលខឹងសម្បានឹងការលើកដំកើនស្ត្រីស្មើបុរសបានបន្តបំផ្លិចបំផ្លាញរូបចម្លាក់របស់ព្រះបញ្ញាបរាមិតាទាំងអស់ ( សូមមើលរូបខាងលើ) ។ ទោះបីជាមានការបំផ្លិចបំផ្លាញយ៉ាងណាក៏ដោយភស្តុតាងទាំងនោះនៅតែជាអំណះអំណាង។ ភ្ញៀវទេសចរណ៍ទាំងអស់ដែលបានមកទស្សនាវិមានដ៏ធំរបស់ប្រាសាទអង្គរធំនៅតែទទួលបាននូវអំណះអំណាងបន្ថែមស្តីពីមនោគមវិជ្ជាផ្តល់តម្លៃឱ្យស្ត្រីនេះ។ ក្នុងរយះពេលជាងប្រាំបីរយឆ្នាំមកនេះភ្ញៀវទេសចរណ៍គ្រប់រូបបានដើរចូល និងចេញតាមខ្លោងទ្វាមួយនៃចំណោមខ្លោងទ្វាទាំងប្រាំរបស់បន្ទាយប្រាសាទអង្គរធំដែលក្សត្រទាំងបីអង្គនេះបានកសាងឡើង។ នៅតាមខ្លោងទ្វានីមួយៗ ក្សត្រទាំងបីព្រះអង្គបានបង្កើតសារដ៏ច្បាស់លាស់ពីជំនឿផ្ទាល់ខ្លួននិងជំនឿផ្លូវចិត្តរបស់ទ្រង់។ ខណៈពេលដែលយើងមកដល់ខ្លោងទ្វារអង្គរធំយើងនឹងឃើញមុខដ៏ធំរបស់ព្រះបាទ

© 2011 All rights reserved. www.phalikan.com 

ជ័យវរ្ម័នទី៧ដែលមានទម្រង់ជាកំពូលបីខុសៗគ្នា ( សូមមើលរូបខាងក្រោម) ដែលមានរាងស្រដៀងគ្នា នឹងមុកុដកំពូលបីដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់គ្រឿងនៅពេលបំពេញតួនាទីនៅតាមសមរភូមិដែលជាសញ្ញាណរូបតំណាង និងនិមិត្តរូបរបស់ក្សត្រទាំងបីអង្គគឺ ព្រះមហាក្សត្រីឥន្ទ្រទេវី ព្រះបាទជ័យវរ្ម័នទី៧ និងព្រះមហាក្សត្រីជ័យរាជទេវី។ ព្រះរាជវង្សដ៏អស្ចារ្យទាំងបីបានចែករំលែកទស្សនវិស័យដ៏រុងរឿងដល់អាណាចក្រខ្មែរ។ ដោយការបង្រួបបង្រួមកម្លាំង និងប្រាជ្ញារបស់បុរស និងស្ត្រី ក្សត្រទាំងបីអង្គបានសម្រេចនូវជោគជ័ក្នុងការអភិវឌ្ឍសង្គមតាមរយៈការផ្តល់សិទ្ធិ និងឱកាសស្មើគ្នាដើម្បីដើរឆ្ពោះទៅរកប្រទេសដែលប្រកបដោយអារ្យធម៌ខ្ពង់ខ្ពស់។

ដូចដែលបានលើកឡើងខាងលើខ្មាំងប្រឆាំងនឹងទស្សននេះបានព្យាយាមបំផ្លិចបំផ្លាញទស្សនៈដ៏ត្រចះត្រចង់ទាំងនេះដោយធ្វើការបំផ្លិចបំផ្លាញរូបចម្លាក់នៅតាមខ្លោងទ្វាប្រាសាទនីមួយៗដែលបង្ហាញពីរូបព្រះរាជាទាំងបីអង្គដូចដែលមានរៀបរាប់នៅក្នុងទ្រឹស្តីរបស់ខ្ញុំ។ ក្រោយពីការបំផ្លិចបំផ្លាញនិមិត្តរូបរបស់ព្រះពុទ្ធ អ្នកកាន់ព្រហ្មញ្ញសាសនាបានដាក់ឈ្មោះថ្មីដើម្បីតំណាងឱ្យព្រះក្នុងព្រហ្មញ្ញសាសនាវិញគឺ សេរ៍ះ ( ឬព្រះព្រហ្ម) ( សូមមើលរូបខាងក្រោម) ។ ប៉ុន្តែភស្តុតាងដើមដែលនៅសេសសល់បានឆ្លុះបញ្ចាំងពីគោលបំណងបំផ្លិចបំផ្លាញនេះជាពិសេសគឺនៅពេលធ្វើការសិក្សាពីរូបបដិមានៃរជ្ជកាលគ្រប់គ្រងដែលនៅសេសសល់។



**ខ្លោងទ្វារខាងជើងរបស់ប្រាសាទអង្គរធំមានផ្ទាំងរូបដំរីក្បាលបីទាំងសងខាង និងកំពូលបូជនីយស្ថានដែលចាក់រូបរាងដោយបង្ហាញឱ្យឃើញពីទម្រង់នៃកំពូលបូជនីយស្ថាននៅពីមុខដ៏ធំរបស់ព្រះបាទជ័យវរ្ម័នទី៧។**

នៅផ្នែកខាងក្រោមនៃខ្លោងទ្វាទាំងសងខាងមានរូបដំរីក្បាលបីរបស់ព្រះឥន្ទ្រដែលជាព្រះរបស់ព្រះហិណ្ឌូ។ នៅត្រង់នេះព្រះបាទជ័យវរ្ម័នទី៧បានយកសត្វដំរីពាក់មកុដដែលកំពូលជាផ្កាឈូកបីជានិមិត្តរូប។ ការផ្លាស់ប្តូរដ៏ទន់ភ្លន់តែមានអំណាចមួយនេះបានឆ្លុះបញ្ចាំងឱ្យយើងទាំងអស់គ្នាឃើញថាដំរីនេះមិនមែនដំរីរបស់ព្រះឥន្ទ្រទេ ប៉ុន្តែគឺជាដំរីរបស់ព្រះបាទជ័យវរ្ម័នទី៧។ ព្រះបាទជ័យវរ្ម័នទី៧បានអមដំណើរដោយព្រះអគ្គមហេសីទាំងពីររបស់ទ្រង់ដែលញញឹមរហូតនៅសងខាងទ្រង់។ ក្សត្រដ៏មានប្រយោជន៍ទាំងបីអង្គនេះបានអង្គុយនៅសងខាងដំរីទាំងបីដោយ

© 2011 All rights reserved. w w w . p h a l i k a n . c o m

ធ្វើការស្វាគមន៍ដល់ភ្ញៀវទេសចរណ៍គ្រប់ៗគ្នា ( សូមមើលរូបខាងក្រោម) ។ ចូរកត់សំគាល់ថារូបក្សត្រទាំងបីព្រះអង្គគង់លើទីតាំងដែលបង្ហាញអំណាចស្មើគ្នាដោយលើកជង្គង់មួយឡើងលើដាក់កែងដៃស្ដាំលើជង្គង់ ហើយនិងដៃស្ដាំកាន់អាវុធ ឬវត្ថុ ( អាវុធដែលមានអានុភាពរបស់ព្រះឥន្ទ ឬព្រះក្នុងសាសនាហិណ្ឌូ) នៅលើដើមទ្រូង។ ព្រះបាទជ័យវរ្ម័នទី៧បានបង្ហាញអោយសាធារណៈជនអំពីឥទ្ធិពលរបស់ម្ចាស់ក្សត្រីឥន្ទ្រទេវី និងម្ចាស់ក្សត្រីជ័យរាជទេវីដែលមានអំណាចទៅលើការគ្រប់គ្រង និងរៀបចំនិតិរដ្ឋ។



**ដំរីដែលមានពាក់ម្កុដកំពូលបីចិតនៅខាងក្រោមរូបក្សត្រទាំងបីអង្គដែលបាត់រូបរាង។**

**ចូរកត់សំគាល់ការគង់លើទីតាំងដែលបង្ហាញពីអំណាចស្មើរបស់ម្ចាស់ក្សត្រីទាំងពីរ និងព្រះមហាក្សត្រ។**

នៅខាងលើព្រះមហាក្សត្រ និងព្រះមហាក្សត្រីទាំងពីរ ទេវតាទាំងប្រាំពីរអង្គ ( រូបបដិមាស្រីដ៏មានបរមីរបស់ខ្មែរ) នៅក្នុងឥរិយាបថប្រណមដៃទាំងពីរនៅលើធ្វើការស្វាគមន៍ និងព្រោះព្រំដល់ភ្ញៀវទេសចរណ៍ទាំងអស់។ មានទេវតានៅអមសងខាងព្រះភ័ក្ដដ៏ធំរបស់ព្រះបាទជ័យវរ្ម័នទី៧ ( សូមមើលរូបខាងក្រោម) ។ ទស្សនៈស្ដីពីក្សត្រទាំងបីអង្គគឺព្រះមហាក្សត្រីពីរអង្គ និងព្រះមហាក្សត្រមួយអង្គត្រូវបានឃើញជាញឹកញាប់។ ដូច្នេះភ្ញៀវទេសចរណ៍គ្រប់ៗគ្នាបានយល់ដឹងពីជំនឿផ្ទាល់ខ្លួន ជំនឿតាមផ្លូវចិត្ត និងជំនឿលើសង្គមរបស់ក្សត្រដឹកនាំនេះជាមួយនឹងភស្តុតាងដែលទាក់ទងអំពីសិទ្ធ និងតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងព្រះរាជណាចក្រនេះ។

© 2011 All rights reserved.




ខ្លោងទ្វារនីមួយៗបានបង្ហាញពីជំនឿរបស់ក្សត្រខ្មែរទាំងបីអង្គ។




ព្រះមហាក្សត្រីឥន្ទ្រទេវី ព្រះបាទជ័យវរ្ម័នទី៧ និងព្រះមហាក្សត្រីជ័យរាជទេវី

ពេលវេលាសម្រាប់ក្មេងជំនាន់ក្រោយក្នុងការយល់ដឹងពីព្រះបាទជ័យវរ្ម័នទី៧ និងព្រះអគ្គមហេសីទាំងពីររបស់ព្រះអង្គតាមរយៈចំណារដ៏ច្បាស់នេះបានមកដល់ហើយ។ បូជនីយស្ថាន ផ្ទាំងសិលាចារឹក និងចម្លាក់លៀនបានបង្ហាញយើងទាំងអស់គ្នាអោយឃើញពីអ្នកដឹកនាំ ដ៏សប្បុរសដែលយកចិត្តទុកដាក់ពីប្រជាពលរដ្ឋរបស់ខ្លួន។ ព្រះមហាក្សត្រ និងម្ចាស់ក្សត្រីទាំងពីរធ្វើការជាមួយគ្នាដើម្បីទទួលបាននូវអ្វីដែលមនុស្សគ្រប់រូបធ្លាប់បានគិតថា វាមិនអាចធ្វើបាននៅក្នុងការកសាងព្រះរាជនគរដ៏រុងរឿងមួយដែលពោរពេញដោយការបង្កើតថ្មីទាំងផ្នែកហេដ្ឋា

© 2011 All rights reserved. www.phalikan.com

វចនាសម្ព័ន សង្គម និងបញ្ញាជាលក្ខណៈសកលកាលពី៨៣០ឆ្នាំមុន។

ក្សត្រដឹកនាំដ៏អស្ចារ្យ ទាំងបីអង្គនេះបានចែករំលែកទស្សនវិស័យដ៏រុងរឿងមួយសម្រាប់ប្រជាពលរដ្ឋទាំងអស់។ ពួកទ្រង់បានធ្វើការរួមគ្នាដោយចងក្រងជាបញ្ញា ការយល់ឃើញដូចគ្នា និងគោលការណ៍ មនុស្សធម៌ ដើម្បីបង្កើតជាព្រះពុទ្ធសាសនាសម្រាប់អាណាចក្ររបស់ទ្រង់ដែលជាមូលដ្ឋាននៃចំណុចខ្លាំងដែលរួមបញ្ចូលទាំងកេរ្តិ៍តំនែលជាតិ ជំនឿសាសនា ជំនឿពូជសាសន៍ និងជំនឿបុគ្គល។

ដូចគ្នានឹងក្សត្រដឹកនាំប្រទេសទាំងអស់ ក្សត្រទាំងបីអង្គនេះដឹកនាំប្រទេសជាគំរូ។ ប្រាំបីរយឆ្នាំក្រោយមក កេរ្តិ៍តំណែលដែលបន្សល់ទុកនៅតាមផ្ទាំងសិលានៅតែឆ្លុះបញ្ចាំងពីជំនឿលើមនុស្សធម៌របស់ទ្រង់។ ស្របពេលដែលប្រាសាទអង្គរវត្តធ្វើឱ្យភ្ញៀវទេសចរណ៍ស្ញប់ស្ញែងនឹងស្ថាបត្យកម្មដ៏ធំសម្បើមនេះ ប្រាសាទបាយ័នក៏ធ្វើឱ្យភ្ញៀវទេសចរណ៍ស្ងើចសរសើរ និងព្រះភ័ក្តដ៏ប្រឹមប្រិយដែលប្រកបដោយស្នាមញញឹមរបស់ព្រះបាទជ័យវរ្ម័នទី៧នៅខាងលើ និងស្នាមញញឹមរបស់ព្រះមហាក្សត្រីទាំងពីរព្រះអង្គនៅផ្នែកខាងក្រោម។ បច្ចុប្បន្ននេះនៅប្រាសាទបាយ័នរូបព្រះបាទជ័យវរ្ម័នទី៧ ព្រះមហាក្សត្រីជ័យរាជទេវី និងព្រះមហាក្សត្រីឥន្ទ្រទេវីបានប្រោះព្រំឱ្យយើងទាំងអស់គ្នានូវស្នាមញញឹមនៃភាពមនុស្សធម៌។




**ព្រះមហាក្សត្រីឥន្ទ្រទេវី ព្រះបាទជ័យវរ្ម័នទី៧ និងព្រះមហាក្សត្រីជ័យរាជទេវី នៅប្រាសាទបាយ័ន**

## អំពីអ្នកនិពន្ធ

**ផិន ផល្លីកា** គឺជាអ្នកថតរូប និងអ្នកស្រាវជ្រាវជនជាតិខ្មែរ សញ្ជាតិអាមេរិកដែលរស់នៅខេត្តសៀមរាប ប្រទេសកម្ពុជា។ គេហទំព័ររបស់នាងគឺ PhalikaN.com បង្ហាញពីការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្ររបស់នាង។ គេហទំព័រនេះក៏ផ្តោតលើភាពប៉ិនប្រសប់ និងសិល្បបុរាណរបស់កម្ពុជា និងបង្ហាញពីផ្ទាំងរូបថតដើមរបស់នាងផងដែរ។ ទស្សនាវដ្តី Cambodia Insight Magazine បានបង្ហាញពីការស្រាវជ្រាវរបស់ ផិន ផល្លីកា ពីព្រះមហាក្សត្រីឥន្ទ្រទេវី និងព្រះមហាក្សត្រជ័យរាជទេវីនៅក្នុងអត្ថបទៈ □ការរស់ឡើងវិញនៃ ព្រះមហាក្សត្រីឥន្ទ្រទេវី និងព្រះមហាក្សត្រី ជ័យរាជទេវី ព្រះមហាក្សត្រីនៃរាជាណាចក្រខ្មែរនាសតវត្សទី១២□ ។

© 2011 All rights reserved. w w w . p h a l i k a n . c o m